រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កំណត់ហេតុ
# មហាសន្និបាតភាគហ៊ុនិកលើកទី៧

**ក/.កាលបរិច្ឆេទ** ៖ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩ ចាប់ពីម៉ោង៨:០០ព្រឹក

**ខ/.ទីកន្លែង** ៖ សាលប្រជុំរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ)

**គ/.សមាសភាពចូលរួម** ៖

- គណៈអធិបតី ៖
  - ១. ឯកឧត្តម សឹម ណារ៉ា ប្រធានក្រុមប្រឹក្សាភិបាល
  - ២. ឯកឧត្តម ស៊ឹម ស៊ីថា អគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
  - ៣. ឯកឧត្តម ម៉ី វ៉ាន់ សមាជិកក្រុមប្រឹក្សាភិបាល - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  - ៤. លោក ឡុង ណារ៉ូ សមាជិកក្រុមប្រឹក្សាភិបាល - តំណាងនិយោជិត
  - ៥. លោកឧកញ៉ា ចាង យុនហ្វេង សមាជិកក្រុមប្រឹក្សាភិបាល - អភិបាលមិនប្រតិបត្តិ តំណាងភាគហ៊ុនិកឯកជន
  - ៦. លោក អោម សេងបូ៉ា សមាជិកក្រុមប្រឹក្សាភិបាល - អភិបាលឯករាជ្យ
- ភ្ញៀវកិត្តិយស ៖
  - ១. ឯកឧត្តម ម៉ី វ៉ាន់ តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  - ២. ឯកឧត្តម យា ប៊ុនណា តំណាងក្រសួងឧស្សាហកម្មនិងសិប្បកម្ម
  - ៣. ឯកឧត្តម នេត មុន្នី មន្ត្រីត្រួតពិនិត្យរដ្ឋ អម រ.ទ.ស.ភ
  - ៤. លោកស្រី សេង គាតារា ប្រធានសវនកម្មផ្ទៃក្នុង រ.ទ.ស.ភ
  - ៥. លោក អាន សុធា តំណាងក្រុមហ៊ុនសវនកម្មឯករាជ្យ ប៊ី ឌី អូ (ខេមបូឌា)
  - ៦. លោកស្រី នាន បូនី តំណាងគណៈកម្មការមូលបត្រកម្ពុជា
  - ៧. លោកស្រី យូ កញ្ញារី តំណាងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
  - ៨. លោក លឹម អាន តំណាងធនាគារអេស៊ីលីដា ភីអិលស៊ី
  - ៩. លោកស្រី លិន លីនដា តំណាងកំពង់ផែស្វយ័តភ្នំពេញ
  - ១០. លោក អ៊ូ សុវណ្ណឫទ្ធិ តំណាងកំពង់ផែស្វយ័តក្រុងព្រះសីហនុ
  - ១១. លោកស្រី យឹម រស្មី តំណាងក្រុមហ៊ុនហ្គ្រេនធ្វីន អ៊ីនធើណេសិនណល ភីអិលស៊ី
  - ១២. កញ្ញា រិទ្ធ បូរ៉ាវី តំណាងក្រុមហ៊ុនភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី
  - ១៣. លោក ម៉ៅ ភិរក្ស តំណាងអេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី
  - ១៤. លោក លីហ៊ួ សេងហ៊ុន តំណាងក្រុមហ៊ុន ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី
  - ១៥. លោក Han Kyung Tae តំណាងក្រុមហ៊ុនយាន់តា (ខេមបូឌា) ស៊ីឃ្យូរីធី ភីអិលស៊ី
  - ១៦. លោកស្រី ស្រៀង គឹមស្រ៊ន់ តំណាងក្រុមហ៊ុន អ អេច ប៊ី ឥណ្ឌូឆាយណា ស៊ីឃ្យូរីធី
  - ១៧. លោក សៀ ម៉ៅ តំណាងក្រុមហ៊ុន កាណា ស៊ីឃ្យូរីធី អិលធីឌី
  - ១៨. លោក ចាង លីងហ្វេង តំណាងក្រុមហ៊ុន ហ្គោលដេន ហ្វ័រឈូន ស៊ីឃ្យូរីធី

- លេខាកត់ត្រា ៖ ១. លោកបណ្ឌិត ជា វិសុទ្ធ អគ្គនាយករងទទួលបន្ទុកជាលេខាសហគ្រាស
២. លោក ហួត សុខហេង នាយលេខាធិការដ្ឋាន។
- អ្នកចូលរួម ៖ ចំនួនភាគហ៊ុនិកដែលបានចុះឈ្មោះនៅភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្ររបស់ រ.ទ.ស.ភ (ធនាគារ អេស៊ីលីដា ភីអិលស៊ី) ដើម្បីត្រៀមចូលរួមមហាសន្និបាតមានចំនួន១៧៧នាក់ គិតជាភាគហ៊ុនមានចំនួន ៧៤.៦០៣.៥៦៤ហ៊ុន ស្មើនឹង៨៥,៧៨%នៃភាគហ៊ុនធម្មតាសរុប។ ភាគហ៊ុនិកដែលបានចុះវត្តមាននិងបានចូលរួមមហាសន្និបាតជាក់ស្តែងមានចំនួន១៣៨នាក់ គិតជាភាគហ៊ុនមានចំនួន៧៤.៤២៦.៩៨៤ហ៊ុន (ស្មើនឹង ៩៩.៧៦%នៃចំនួនភាគហ៊ុនដែលបានចុះឈ្មោះចូលរួម) ក្នុងនោះមានលោក ប៉ូ សំអាង អនុប្រធាននាយកដ្ឋានទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ ជាតំណាងអាណត្តិគាហកៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដោយឡែកភាគហ៊ុនិកដែលមិនបានចុះវត្តមាន តែបានចូលរួមមហាសន្និបាត មានចំនួន៨៤នាក់។

## ឃ/.ដំណើរការនៃមហាសន្និបាត

ជាកិច្ចចាប់ផ្តើម **ឯកឧត្តម សឹម ណារ៉ា** ប្រធានក្រុមប្រឹក្សាភិបាល រ.ទ.ស.ភ និងជាប្រធានគណៈអធិបតី នៃអង្គមហាសន្និបាត បានថ្លែងសន្ទរកថាស្វាគមន៍បើកដំណើរការមហាសន្និបាតភាគហ៊ុនិកលើកទី៧ ក្នុងគោលបំណងដើម្បីរាយការណ៍ជូនភាគហ៊ុនិកទាំងអស់បានជ្រាបអំពីលទ្ធផលអាជីវកម្មឆ្នាំ២០១៨ និងទិសដៅអាជីវកម្មឆ្នាំ២០១៩ របស់ រ.ទ.ស.ភ ។ ក្នុងសន្ទរកថានោះ ឯកឧត្តមបានជម្រាបត្រួសៗជូនអង្គមហាសន្និបាត អំពីលទ្ធផលអាជីវកម្មដែល រ.ទ.ស.ភ ខិតខំសម្រេចបានក្នុងឆ្នាំ២០១៨កន្លងទៅ ដោយផលិតទឹកស្អាតសរុបបាន ២០៨.៩០៤.៧១៩ម៣ ដាក់បណ្តាញចែកចាយទឹកថ្មីបានប្រវែង ២៥៦,៦៥គ.ម តបណ្តាញចូលផ្ទះថ្មីបានចំនួន ៣៣.៧៤៤៣បណ្តាញ (ក្នុងនោះបណ្តាញអតិថិជនចំណូលទាបមានចំនួន៥៣១គ្រួសារ) និងរក្សាអត្រាទឹកបាត់បង់ត្រឹមកម្រិត ៨,១៨%។ ក្រៅពីនេះ ចំណូលសរុបមានចំនួន ២៦៥.០៩៣លានរៀល និងចំណេញក្រោយបង់ពន្ធមានចំនួន ៧៣.៦០៧លានរៀល។ ចំណេញជាមូលដ្ឋានក្នុងមួយភាគហ៊ុន (Basic Earnings per Share) គឺ ៨៤៦,៣២រៀល។

ឯកឧត្តមប្រធានគណៈអធិបតី ក៏បានមានប្រសាសន៍បន្ថែមទៀតថា ៖ ក្រោយពីការបែងចែកប្រាក់ចំណេញតាមលក្ខន្តិកៈ រ.ទ.ស.ភ ក្នុងសម័យប្រជុំលើកទី១១ កាលពីថ្ងៃទី២៩ខែមីនាកន្លងទៅ ក្រុមប្រឹក្សាភិបាលបានឯកភាពជាឯកច្ឆ័ន្ទ រក្សាទុកប្រាក់ចំណេញចំនួន ៤៧.៣២១.០៩១.១៤៨រៀល សម្រាប់ការវិនិយោគទៅអនាគត និងទឹកប្រាក់នៅសល់ចំនួន ១៨.៩២៥.៣៦០.០៥១រៀល សម្រាប់បែងចែកភាគលាភជូនភាគហ៊ុនិក។

បើធៀបទៅនឹងឆ្នាំ២០១៧ ប្រាក់ចំណេញបានកើនឡើង២២,៦%។ ហេតុនេះហើយ ទើបក្រុមប្រឹក្សាភិបាលបានសម្រេចបែងចែកភាគលាភ (Dividend per share) ចំនួន ២១៧,៦០រៀលក្នុងមួយភាគហ៊ុន (កើនលើសឆ្នាំមុនប្រមាណ៤១%) ដែលមានទិន្នផលភាគលាភ (Dividend Yield) ស្មើនឹង៤%។ ភាគលាភនេះបានចាប់ផ្តើមទូទាត់ជូនភាគហ៊ុនិក ចាប់ពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩។

ដើម្បីជាព័ត៌មានលម្អិត ឯកឧត្តមបានស្នើឲ្យលោក រស់ គឹមលាង អគ្គនាយករងទទួលបន្ទុកហិរញ្ញកិច្ចនិងផ្សារមូលបត្រ ធ្វើបទបង្ហាញជូនអង្គមហាសន្និបាត។

## ១/.បទបង្ហាញស្តីពីលទ្ធផលអាជីវកម្មឆ្នាំ២០១៨ និងទិសដៅអាជីវកម្មឆ្នាំ២០១៩

លោក រស់ គឹមលាង អគ្គនាយករងទទួលបន្ទុកហិរញ្ញកិច្ចនិងផ្សារមូលបត្រ បានធ្វើរបាយការណ៍លម្អិតជូនអង្គមហាសន្និបាតជ្រាបអំពីលទ្ធផលអាជីវកម្មឆ្នាំ២០១៨ និងទិសដៅអាជីវកម្មឆ្នាំ២០១៩ តាមរយៈការបញ្ចាំងស្លាយជាភាសាខ្មែរនិងភាសាអង់គ្លេស ដោយមានខ្លឹមសារសំខាន់ៗ ដូចមានក្នុងឯកសារសម្រាប់មហាសន្និបាត។ លោកក៏បានធ្វើការកត់សម្គាល់ផងដែរថា ៖

- នៅក្នុងអង្គការលេខរបស់ រ.ទ.ស.ភ មានការបង្កើតបន្ថែមនូវការិយាល័យទីផ្សារ និងសេវាកម្ម នៅក្នុងសាខាសេវាកម្មទឹកស្អាត និងអនាម័យ ដើម្បីជម្រុញ និងពង្រីកវិសាលភាពនៃសេវាកម្ម និងអនាម័យឲ្យកាន់តែទូលំទូលាយ។ តាមលក្ខន្តិកៈដែលអនុម័តដោយក្រសួងអាណាព្យាបាលទាំងពីរ គឺក្រសួងឧស្សាហកម្ម និងសិប្បកម្ម និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម រ.ទ.ស.ភ មានសិទ្ធិផ្តល់សេវាកម្ម និងអនាម័យទាំងក្នុង និងក្រៅប្រទេស ក្នុងគោលបំណងសំខាន់គឺបង្កើនចំណូលបន្ថែម នៅក្រោយពេល រ.ទ.ស.ភ បានចុះបញ្ជីក្នុងផ្សារមូលបត្រកម្ពុជា។

- កាតព្វកិច្ចសោធននិវត្ត (ដែលតម្រូវឲ្យមន្ត្រី-និយោជិតម្នាក់ៗបង់ប្រាក់ប្រចាំខែស្មើនឹង ៧% នៃប្រាក់បៀវត្សរ៍របស់ខ្លួន ហើយអង្គភាពបង់ ៥% នៃប្រាក់បៀវត្សរ៍របស់មន្ត្រី-និយោជិតម្នាក់ៗប្រចាំខែ និង ២% នៃប្រាក់ចំណេញពិតប្រចាំឆ្នាំនីមួយៗ) នឹងឈប់អនុវត្តចាប់ពីឆ្នាំ២០១៩តទៅ។ ចាប់តាំងពីឆ្នាំ១៩៩៧ រ.ទ.ស.ភ បានបង្កើតមូលនិធិសោធននិវត្តផ្ទៃក្នុងមួយសម្រាប់មន្ត្រី-និយោជិតរបស់ខ្លួន តែមិនគ្រប់គ្រងដោយរដ្ឋទេ ដោយផ្អែកតាមអនុសញ្ញាស្តីពីការចូលនិវត្តនិងបាត់បង់សម្បទានវិជ្ជាជីវៈរបស់ រ.ទ.ស.ភ ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។ រហូតមកដល់ដើមឆ្នាំ២០១៨ មូលនិធិនេះមានទឹកប្រាក់ជាង ៤០ពាន់លានរៀល ដែលត្រូវបានរំលេចជាបំណុលរបស់ រ.ទ.ស.ភ ចំពោះមន្ត្រី-និយោជិត។ ដោយឡែកនាសម័យប្រជុំវិសាមញ្ញលើកទី១ ឆ្នាំ២០១៩ កាលពីថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩ ក្រុមប្រឹក្សាភិបាលបានអនុម័ត-សម្រេចជាឯកច្ឆន្ទ បញ្ចប់នូវអនុសញ្ញានេះ ដោយប្រគល់ជូនមន្ត្រី-និយោជិតម្នាក់ៗវិញ នូវទឹកប្រាក់វិភាគទានសរុបចំនួន៧% ដែលពួកគាត់បានបង់កន្លងមក រួមទាំងការប្រាក់។ រីឯប្រាក់នៅសល់ប្រមាណ ៣២ពាន់លានរៀល នឹងបង្វែរទៅជាចំណូលរបស់អង្គភាព។

- បណ្តាសន្ទស្សន៍សំខាន់ៗដែលសម្រេចបានក្នុងឆ្នាំ២០១៨ គឺ ៖

| | | |
|---|---|---|
| ១. | អនុបាតចរន្ត | ១,៧៩ ដង |
| ២. | អត្រាអនុបាតចរន្តលឿន | ១,១៥ ដង |
| ៣. | ផលចំណេញក្នុងមួយឯកតាទ្រព្យសកម្ម | ៥,២៤% |
| ៤. | ផលចំណេញក្នុងមួយឯកតាមូលធន | ៨,៤៧% |
| ៥. | អត្រាទឹកបាត់បង់ | ៨,១៨% |
| ៦. | អត្រាទារប្រាក់ | ៩៩,៩០% |

- ទិសដៅសំខាន់ៗនៃអាជីវកម្មក្នុងឆ្នាំ២០១៩ គឺ ៖

| | | |
|---|---|---|
| ១. | ដាក់បណ្តាញចែកចាយទឹកស្អាតបន្ថែម | ២៥០ គ.ម |
| ២. | តបណ្តាញចូលផ្ទះថ្មីចំនួន | ២២.០០០ បណ្តាញ |
| ៣. | ចំនួនអតិថិជនចុងគ្រានាដំណាច់ឆ្នាំ២០១៩ | ៣៨៤.៣០០ បណ្តាញ |
| ៤. | បរិមាណទឹកលក់ | ១៩៦.១៣៧.៨៦៤ $ម^៣$ |
| ៥. | បរិមាណទឹកផលិត | ២១៣.៨៩០.៨០០ $ម^៣$ |
| ៦. | អត្រាធ្វើវិក្កយបត្រ | ៩១,៧០% |
| ៧. | អត្រាទារប្រាក់ | ៩៩,៩០% |
| ៨. | ថ្លៃទឹកលក់ជាមធ្យម/$ម^៣$ | ១.០១០ រៀល |
| ៩. | ចំណូលសរុប | ២៤៦.៥៩៣.៣៧៤.០០០ រៀល |
| ១០. | ចំណាយសរុប | ១៩២.៧៧៩.៩៨១.០០០ រៀល |
| ១១. | ចំណេញពិត | ៥៣.០៥០.៧១៤.០០០ រៀល |

- រ.ទ.ស.ភ នឹងធ្វើការកែសម្រួលតម្លៃទឹករបស់ខ្លួន ផ្អែកទៅតាមការឯកភាពជាគោលការណ៍ពីប្រមុខរាជរដ្ឋាភិបាល កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៩ ដោយត្រូវអនុវត្តចាប់ពីឆ្នាំ២០២០តទៅ ក្នុងនោះអ្នកប្រើប្រាស់តិចនឹងទទួលបានការបញ្ចុះថ្លៃបន្ថែម រីឯអ្នកប្រើប្រាស់ច្រើននឹងជួយដល់អ្នកប្រើប្រាស់តិច។ ជាក់ស្តែង តម្លៃទឹកដែល រ.ទ.ស.ភ កំពុងអនុវត្តបច្ចុប្បន្ន ពុំធ្លាប់ត្រូវបានកែសម្រួលទេ ចាប់តាំងពីឆ្នាំ២០០១មកម្ល៉េះ ហើយការកើនឡើងនៃថ្លៃលក់ទឹកជាមធ្យម គឺដោយសារតែកំណើននៃចំនួនអតិថិជនប្រភេទអាជីវកម្មតែប៉ុណ្ណោះ។ ក្នុងស្ថានភាពបច្ចុប្បន្ន រ.ទ.ស.ភ ចំណេញពីការលក់ទឹកមិនដល់២០រៀល/ម៣ ផងខណៈថ្លៃដើមទឹកជាមធ្យម គឺប្រមាណ៩៨៦រៀល/ម៣។ ដើម្បីជានយោបាយ "ទឹកចិញ្ចឹមទឹក" ដោយធ្វើយ៉ាងណាឲ្យអង្គភាពអាចដំណើរការដោយរលូន មានលទ្ធភាពផ្គត់ផ្គង់ទឹកស្អាត និងបម្រើសេវាកម្មបានល្អជូនអតិថិជន ការកែសម្រួលតម្លៃទឹក គឺជាវិធីចាំបាច់តែមួយគត់ដែលត្រូវអនុវត្ត ព្រោះថាអត្រាទឹកបាត់បង់ (បច្ចុប្បន្ន ៨,១៨%) មិនអាចកាត់បន្ថយឲ្យទាបជាងនេះបានទេ។

- ហេតុអ្វីបានជាសម្ពាធទឹករបស់ រ.ទ.ស.ភ នៅតាមតំបន់សេវាមួយចំនួន មានកម្រិតទាបនាបច្ចុប្បន្ន?
ផ្អែកតាមការព្យាករណ៍នៅក្នុងផែនការមេលើកទី២ តម្រូវការទឹកពីឆ្នាំ២០០៥-២០២០ ស្ថិតនៅក្រោមឆ្ងាយពីសមត្ថភាពផលិត។ ប៉ុន្តែជាក់ស្តែង តម្រូវការទឹកបច្ចុប្បន្នលើសពីសមត្ថភាពផលិតទៅទៀត។ តើ រ.ទ.ស.ភ បានទឹកមកពីណាសម្រាប់ផ្គត់ផ្គង់? ជាការពិត រ.ទ.ស.ភ ខិតខំកែច្នៃធ្វើយ៉ាងណាឲ្យសមត្ថភាពរបស់រោងចក្រនីមួយៗអាចផលិតបានខ្ពស់ជាងសមត្ថភាពដើមរបស់វា។ ម្យ៉ាងទៀត រ.ទ.ស.ភ មានគោលនយោបាយ "ទឹកស្អាតសម្រាប់ទាំងអស់គ្នា" ដែលអនុញ្ញាតឲ្យអតិថិជនចំណូលទាបរស់នៅជាយរាជធានីភ្នំពេញអាចទទួលបានទឹកស្អាតពី រ.ទ.ស.ភ ផងដែរ។ ទាំងនេះគឺជាកត្តាដែលនាំឲ្យសម្ពាធទឹកធ្លាក់ចុះនៅក្នុងតំបន់សេវាមួយចំនួន នាពេលបច្ចុប្បន្ន។ ទោះបីជាយ៉ាងណា រ.ទ.ស.ភ ក៏បានកសាងផែនការមេលើកទី៣ (ឆ្នាំ២០១៦-២០៣០) រួចរាល់ហើយដែរ។

- ផ្អែកលើផែនការមេលើកទី៣ខាងលើ និន្នាការខ្វះទឹកសម្រាប់ផ្គត់ផ្គង់ជូនអតិថិជន នឹងបន្តរហូតដល់ឆ្នាំ២០២២។ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ ជាបណ្តើរៗ រ.ទ.ស.ភ បាននិងកំពុងអនុវត្តគម្រោងពង្រីកសមត្ថភាពរបស់រោងចក្រផលិតទឹកស្អាតចំការមន ពី២០.០០០ម៣/ថ្ងៃ ដល់៥២.០០០ម៣/ថ្ងៃ ដែលគ្រោងនឹងដាក់ឲ្យដំណើរការនាខែតុលា ឆ្នាំ២០១៩នេះ ព្រមទាំងគម្រោងសាងសង់រោងចក្ររោងចក្របាក់ខែងដំហានទី១ សមត្ថភាពផលិត១៩៥.០០០ម៣/ថ្ងៃ ដែលនឹងចាប់ផ្តើមនាចុងឆ្នាំ២០១៩នេះដែរ។ ក្រៅពីនេះ រ.ទ.ស.ភ ក៏មានគម្រោងសាងសង់រោងចក្រផលិតទឹកស្អាតចំនួន២ ទៀត គឺរោងចក្របាក់ខែង ដំហានទី២ សមត្ថភាពផលិត១៩៥.០០០ម៣/ថ្ងៃ និងរោងចក្រតាខ្មៅ សមត្ថភាពផលិត៣០.០០០ម៣/ថ្ងៃ ដែលគ្រោងនឹងចាប់ផ្តើមអនុវត្តព្រមគ្នាក្នុងឆ្នាំ២០២២។

## ២/. សំណួរ-ចម្លើយ

មានភាគហ៊ុនិកតែម្នាក់គត់ គឺលោក Joseph J. Hoess នាយកនៃក្រុមហ៊ុន Dragon Capital Clean Development Ltd ដែលធ្លាប់បានសរសេរលិខិតតវ៉ាអំពីករណីពន្យារអាណត្តិលើកទី២របស់អភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន (រយៈពេលសរុប៩ឆ្នាំ) បានលើកសំណូមពរ និងផ្តល់អនុសាសន៍ថា ៖ ការជ្រើសតាំងអភិបាល ជាពិសេសអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន គួរត្រូវបានធ្វើតាមរយៈការបោះឆ្នោតដោយភាគហ៊ុនិកឯកជន ដូចដែល រ.ទ.ស.ភ ធ្លាប់បានធ្វើនៅក្នុងមហាសន្និបាតភាគហ៊ុនិកលើទី១

របស់ខ្លួន កាលពីឆ្នាំ២០១៣ នៅរៀងរាល់៣ឆ្នាំម្តង ដើម្បីធានាបាននូវតម្លាភាពក្នុងការអនុវត្តអភិបាលកិច្ចសាជីវកម្ម ទោះបីជាត្រូវបានអនុញ្ញាតដោយច្បាប់ ឬបទបញ្ញត្តិណាមួយក៏ដោយ។

ឆ្លើយតបនឹងសំណូមពរនេះ ឯកឧត្តមប្រធានគណៈអធិបតី បានមានប្រសាសន៍ថា ៖ ពាក់ព័ន្ធនឹងការជ្រើសតាំងអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ក្រុមប្រឹក្សាភិបាល រ.ទ.ស.ភ បានធ្វើលិខិតឆ្លើយតបជាផ្លូវការជូនទៅលោករួចហើយ។ ឯកឧត្តមប្រធានក៏បានបញ្ជាក់ផងដែរថា អ្វីៗដែលយើងអនុវត្តកន្លងមក គឺស្របទៅតាមបទដ្ឋានគតិយុត្តិរបស់ព្រះរាជាណាចក្រកម្ពុជា។

## ៣/. មតិបញ្ចប់ និងសេចក្តីថ្លែងអំណរគុណ

ផ្អែកលើលទ្ធផលលម្អិតដែលលើកឡើងក្នុងបទបង្ហាញខាងលើ ឯកឧត្តមប្រធានគណៈអធិបតី បានវាយតម្លៃថា ៖ រ.ទ.ស.ភ បានទទួលជោគជ័យក្នុងប្រតិបត្តិការរបស់ខ្លួននាឆ្នាំ២០១៨កន្លងទៅ ហើយក្នុងឆ្នាំ២០១៩នេះ រ.ទ.ស.ភ ត្រូវបន្តប្រតិបត្តិការរបស់ខ្លួន ដើម្បីជោគជ័យជាបន្តទៅទៀត ដោយក្នុងនោះគ្រោងនឹងលក់ទឹកបានជាង២១៤លានម៣ ជាមួយនឹងការតបណ្តាញចែកចាយថ្មីបន្ថែមប្រវែង ២៥០គ.ម និងបណ្តាញអតិថិជនថ្មីចំនួន ២២.០០០បណ្តាញ។ យើងគ្រោងថានឹងមានចំណូលសរុបប្រមាណ ២៤៦.៥៩៣លានរៀល ដោយគ្រោងចំណេញក្រោយបង់ពន្ធប្រមាណជាង៤៣.០៥០លានរៀល។

ដើម្បីឈានទៅសម្រេចទិសដៅខាងលើ យើងគ្រោងនឹងដាក់ឲ្យដំណើរការរោងចក្រផលិតទឹកស្អាតចំការមន ដែលមានសមត្ថភាព៥២.០០០ម៣/ថ្ងៃ នាខែតុលាឆ្នាំ២០១៩ខាងមុខ បន្ថែមលើសមត្ថភាពផលិតបច្ចុប្បន្ន ៥៦០.០០០ ម៣/ថ្ងៃ។ ដូចនេះ នៅចុងឆ្នាំ២០១៩ សមត្ថភាពផលិតសរុបនឹងកើនដល់ ៦១២.០០០ម៣/ថ្ងៃ ដែលនៅពុំទាន់អាចបំពេញតម្រូវការប្រើប្រាស់ប្រចាំថ្ងៃរបស់អតិថិជនបានពេញលេញនៅឡើយ។

ជាមួយគ្នានោះ ដើម្បីបន្តចូលរួមចំណែកសម្រេចឲ្យបាននូវ ***គោលនយោបាយទឹកស្អាតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលកំណត់ថា "ប្រជាពលរដ្ឋរស់នៅតាមទីក្រុង និងទីប្រជុំជនទូទាំងប្រទេស នឹងទទួលបាននូវការផ្គត់ផ្គង់ទឹកស្អាត ១០០% នៅឆ្នាំ២០២៥"*** រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដោយមានការចង្អុលបង្ហាញ និងគាំទ្រពេញទំហឹងពីសំណាក់ក្រសួងអាណាព្យាបាលទាំង២ គឺក្រសួងឧស្សាហកម្មនិងសិប្បកម្ម និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសហការយ៉ាងជិតស្និទជាមួយដៃគូអភិវឌ្ឍ ដើម្បីឈានទៅអនុវត្តគម្រោងពង្រីកសមត្ថភាពប្រព្រឹត្តកម្មទឹកស្អាតចំនួន៣បន្ថែមទៀតគឺ ៖

១) គម្រោងសាងសង់រោងចក្របាក់ខែងដំហានទី១ សមត្ថភាពផលិត ១៩៥.០០០ម៣/ថ្ងៃ ចាប់ផ្តើមក្នុងខែតុលា ឆ្នាំ២០១៩ និងគ្រោងបញ្ចប់ក្នុងឆ្នាំ២០២២។
២) គម្រោងសាងសង់រោងចក្របាក់ខែងដំហានទី២ សមត្ថភាពផលិត ១៩៥.០០០ម៣/ថ្ងៃ ចាប់ផ្តើមក្នុងឆ្នាំ ២០២២ និងគ្រោងបញ្ចប់ក្នុងឆ្នាំ២០២៤។
៣) គម្រោងសាងសង់រោងចក្រតាខ្មៅ សមត្ថភាពផលិត ៣០.០០០ម៣/ថ្ងៃ ចាប់ផ្តើមក្នុងឆ្នាំ២០២២ និងគ្រោងបញ្ចប់ក្នុងឆ្នាំ២០២៤។

ឯកឧត្តមប្រធានគណៈអធិបតី ក៏បានបញ្ជាក់ជូនអង្គមហាសន្និបាតផងដែរថា នាឆ្នាំ២០២០ខាងមុខ យើងនឹងមានការកែសម្រួលថ្លៃទឹក តាមរយៈប្រកាសអន្តរក្រសួងធ្វើឡើងដោយក្រសួងឧស្សាហកម្មនិងសិប្បកម្ម និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ឆ្លៀតឱកាសនេះដែរ ខ្ញុំក៏សូមថ្លែងសរសើរ ចំពោះគណៈកម្មការរៀបចំ និងដំណើរការមហាសន្និបាតភាគហ៊ុនិក លើកទី៧ ដែលបានខ្នះខ្នែងធ្វើឱ្យមហាសន្និបាតនេះ ប្រព្រឹត្តទៅដោយរលូន។

ជាកិច្ចបញ្ចប់នៃមហាសន្និបាត ឯកឧត្តមប្រធានគណៈអធិបតីនៃអង្គមហាសន្និបាត បានថ្លែងអំណរគុណចំពោះ គណៈអធិបតី ភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិ និងសមាជិកនៃអង្គសន្និបាតទាំងមូល ដែលបានអញ្ជើញចូលរួម និងបាន ធ្វើឱ្យមហាសន្និបាតភាគហ៊ុនិកលើកទី៧របស់ រ.ទ.ស.ភ ប្រព្រឹត្តទៅដោយជោគជ័យ។

មហាសន្និបាតបានបញ្ចប់នាម៉ោង១០:៣០នាទីព្រឹក នៃថ្ងៃនិងខែឆ្នាំដដែល។

**លេខាធិការសហាគ្រាស**

បណ្ឌិត.**ជា វិសុទ្ធ**

**ប្រធានគណៈអធិបតីនៃអង្គមហាសន្និបាត**
**ប្រធានក្រុមប្រឹក្សាភិបាល**

**ស៊ឹម_ណារ៉ា**

**<u>កន្លែងទទួល</u> :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- មន្ត្រីត្រួតពិនិត្យរដ្ឋអមរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- គណៈកម្មការមូលបត្រកម្ពុជា
  *"ដើម្បីជូនជ្រាប"*
- គ្រប់អង្គភាពចំណុះរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
  *"ដើម្បីមុខការ"*
- ឯកសារនិងកាលប្បវត្តិ។